នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 08:37
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស
ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញាអន្តរជាតិ
ដាក់ជូន: សហចៅក្រមស៊ើបអង្កេត
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់
ចំណាត់ថ្នាក់ឯកសារដោយ កសចស: **សម្ងាត់/Confidential**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# សំណើលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញាអន្តរជាតិ:**
Andrew CAYLEY

**ផ្ញើជូន៖**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត:**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Siegfried BLUNK

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញាជាតិ:**
ជា លាង

# ពាក្យសុំឲ្យទទួលស្គាល់ចំពោះសុពលភាពនៃសំណើ សុំឲ្យបំពេញកិច្ចស៊ើបសួរ

១. កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសំរេចរបស់ខ្លួនលើសំណើសុំពន្យាពេលបន្ថែម និងសុំឲ្យបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងដោយសព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿងលេខ០០៣ ("ដីកាសម្រេច")[1] ដែលតាមដីកាសំរេចនេះ សហចៅក្រមស៊ើបអង្កេតបានបដិសេធនូវសំណើសុំចំនួនបួនដែលបានដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង ថាគ្មានសុពលភាព៖ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរចំនួនបីដែលរួមមាន សំណើសុំក្នុងពេលនេះ[2] និងសំណើមួយដែលសុំឲ្យពន្យារពេលកំណត់សំរាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០៣[3] ។ អនុលោមតាមវិធាន៣៩.៤ នៃវិធានផ្ទៃក្នុង និងមាត្រា ៨ និង៩ នៃសេចក្ដីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខ អវតក សហព្រះរាជអាជ្ញាអន្តរជាតិសូមដាក់ជូនសារជាថ្មីឡើងវិញនូវសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ និងសូមស្នើឲ្យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់នូវសុពលភាពនៃសំណើសុំនេះ ថាជាបណ្ដឹងដែលកំពុងតែអនុវត្តនៅបន្ទាប់ពីការផុតនៃពេលវេលាកំណត់ ដោយផ្អែកតាមការដែលខ្លួនយល់ឃើញថាជាការសមស្រប។

២. មូលដ្ឋាននៃការការដាក់សំណើនេះសារជាថ្មី នៅក្រោយពេលហួសកំណត់ដែលបានចែងនៅក្នុងវិធាន៦៦.១ នៃវិធានផ្ទៃក្នុង គឺថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចស្ដីពីការបកស្រាយរបស់ខ្លួនពាក់ព័ន្ធទៅនឹងទម្រង់បែបបទ ដែលចាំបាច់សម្រាប់ឲ្យសហព្រះរាជអាជ្ញាណាមួយដាក់សំណើសុំបែបដូច្នេះ តែម្នាក់ឯង ។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនេះត្រូវបាន

[1] ដីកាសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣ របស់ កសចស, D20/3, ថ្ងៃទី៧ មិថុនា ២០១១ ("ដីកាសម្រេច") ។

[2] សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្ដីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ, ថ្ងៃទី១៨ ឧសភា ២០១១, D17 ។ សំណើលើកទី២ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស, ថ្ងៃទី១៨ ឧសភា ២០១១, D18 ។ សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ, ថ្ងៃទី១៨ ឧសភា ២០១១, D19 ។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០៣ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដាក់ដោយ ទាក់ទងនឹងសំណុំរឿងលេខ០០៣, ថ្ងៃទី១០ ឧសភា ២០១១, D15 ។

ច្រានចោលដោយមានមូលដ្ឋាននៅលើបច្ចេកទេសនៃនីតិវិធីចំនួនពីរ និងមិនត្រូវបានពិចារណាលើអង្គសេចក្ដីរបស់វាឡើយ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដើម្បីឱ្យសហព្រះរាជអាជ្ញាណាមួយម្នាក់ចាត់វិធានការតែម្នាក់ឯង គឺវាត្រូវតែមានការផ្ទេរនូវសិទ្ធិអំណាចតាមផ្លូវការ ទៅតាមវិធាន១៣.៣ ឬ ការខ្វែងយោបល់ត្រូវបានចុះបញ្ជី ដោយអនុលោមវិធាន៧១.១ នៃវិធានផ្ទៃក្នុង[4] ។ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិកំពុងប្ដឹងឧទ្ធរណ៍ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត លើវិធានផ្ទៃក្នុងទាក់ទងទៅនឹងការចុះបញ្ជីលើការខ្វែងយោបល់គ្នា សហព្រះរាជអាជ្ញាឥឡូវនេះ បានធ្វើការកត់ត្រានូវចរិតលក្ខណៈចំៗនៃការខ្វែងយោបល់របស់ពួកខ្លួន ដែលទាក់ទងទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ នៅលើឯកសារមួយដែលបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទនៅថ្ងៃនេះ ហើយបានដាក់វាចូលទៅក្នុងបញ្ជីខ្វែងយោបល់គ្នាមួយ ដែលត្រូវបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ។

៣. ដោយសារសំណុំបែបបទមួយក្នុងចំណោមសំណុំបែបបទនានា ដែលចាត់ទុកថាចាំបាច់ត្រូវធ្វើតាមរយៈសេចក្ដីសំរេចឥឡូវនេះត្រូវបានបំពេញសព្វគ្រប់ ហើយមិនមានធ្វើឱ្យខូចដល់បណ្ដឹងឧទ្ធរណ៍ដែលត្រូវដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញា សូមស្នើដល់សហចៅក្រមស៊ើបអង្កេតមេត្តាទទួលស្គាល់ថា សំណើសុំឱ្យបំពេញកិច្ចស៊ើសួរនេះមានសុពលភាព ហើយឥឡូវនេះសូមឱ្យមេត្តាធ្វើការពិនិត្យលើអង្គសេចក្ដី។ ការអនុវត្តនូវឆន្ទានុសិទ្ធិតាមរបៀបនេះនឹងធានាឱ្យប្រាកដថា បច្ចេកទេសក្នុងការគ្រប់គ្រងផ្នែកច្បាប់ គឺមិនជាឧបសគ្គរាំងដល់ភាពត្រឹមត្រូវភាពប្រាកដប្រជានៃច្បាប់ និងតម្លាភាពនៃដំណើរការនីតិវិធីអនុលោមតាមវិធាន២១.១នៃវិធានផ្ទៃក្នុង ហើយនឹងសិទ្ធិជាមូលដ្ឋានរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការធ្វើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរជាបន្ថែមទៀត នៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរអនុលោមតាមវិធាន៦៦.១ នៃវិធានផ្ទៃក្នុង។

## សេចក្ដីផ្ដើម

៤. អនុលោមតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ តាមរយៈនេះ បានដាក់ជូន

---

[4] ដីកាសម្រេច, កថាខណ្ឌទី ៥ ។

សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នូវសំណើលើកទី២ សុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស (“សំណើ”) នេះ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ ដែលត្រូវបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ជាពិសេសមន្ទីរសន្តិសុខ ស២២ និងទាក់ទិនទៅនឹងសិទ្ធិអំណាច និងភាពពាក់ព័ន្ធរបស់លោក ស៊ូ មេត នៅក្នុងបទឧក្រិដ្ឋទាំងអស់នេះ ក្នុងនាមជាប្រធានកងពលធំ ៥០២, កងទ័ពអាកាសរបបកម្ពុជាប្រជាធិបតេយ្យ[៥]។

៥. សំណើនេះ ទាញការយកចិត្តទុកដាក់ចំពោះផ្នែកជាក់លាក់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទី២ ដែលកិច្ចស៊ើបសួរបន្ថែមដ៏សំខាន់ត្រូវធ្វើឡើងជាចាំបាច់ និងកំណត់ដំណាក់កាលស៊ើបសួរជាក់លាក់ដែលត្រូវធ្វើឡើងដោយ ស.ច.ស។ កិច្ចស៊ើបសួរដល់ទីកន្លែងដែលត្រូវបានកំណត់បំផុត រួមទាំងការវិភាគអង្គច្បាប់ និងការវិភាគអង្គហេតុ ត្រូវបានធ្វើឡើងមកទល់ពេលនេះ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស២២ ព្រមទាំងជនជាប់សង្ស័យ ស៊ូ មេត។ វាជាគំនិតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា កិច្ចស៊ើបសួរដែលបានធ្វើឡើង មិនអាចចាត់ទុកថាបានចប់សព្វគ្រប់ហើយនោះទេ។ សហព្រះរាជ-អាជ្ញាអន្តរជាតិបានយោង និងបានបញ្ចូលជាសំអាង នូវការអង្កេតរបស់ខ្លួននៅក្នុងកថាខណ្ឌ ៣ ដល់ ១៤ នៃសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ នៅក្នុងរឿងក្តីនេះ។

៦. ពុំមានកិច្ចស៊ើបសួរបន្ថែមណាមួយត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ដែលជាការយកចិត្តទុកដាក់នៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស បន្ថែមនៅក្នុងសំណុំរឿងលេខ ០០២ នោះទេ លើកលែងតែចំពោះការផ្ទេរឯកសារសំណុំរឿងលេខ ០០២ ទៅសំណុំរឿងលេខ ០០៣[៦] និងបញ្ហានៃតួនាទី និងការទទួលខុសត្រូវជាក់លាក់របស់លោក ស៊ូ មេត ប៉ុណ្ណោះ។

---

[៥] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ, ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, D1/1។

[៦] សំណើសុំធ្វើកិច្ចស៊ើបសួរបន្ថែមលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្មសំណុំរឿង០០៣, ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១។

## មន្ទីរសន្តិសុខ ស២២

## ស្ថានភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស២២

៧. សាក្សីតែម្នាក់គត់ដែលត្រូវបានស្តាប់យកចម្លើយពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស២២ ឈ្មោះ ស្រេង ធី បានបញ្ជាក់អះអាងពីវត្តមានមន្ទីរ ស២២ ដែលមានទីតាំងស្ថិតនៅក្នុងទីក្រុងភ្នំពេញ តំបន់ស្ទឹងមានជ័យ ក្បែរវិទ្យាល័យ ជា ស៊ីម សាមគ្គី បច្ចុប្បន្ន (កាលពីមុនហៅថា សាលាទឹកល្អក់) និងបានដំណើរការក្រោមបទបញ្ជារបស់កងពលធំ ៥០២ ចាប់ពីដើមឆ្នាំ ១៩៧៦ យ៉ាងហោចណាស់ក៏បន្តរហូតដល់ឆ្នាំ ១៩៧៨ ដែរ[៧]។ បរិវេណមន្ទីរសន្តិសុខ មានសាលធំៗបីដែលហ៊ុំព័ទ្ធដោយខ្សែលួសបន្លា ដែលជាកន្លែងអ្នកទោសកម្រិតស្រាលនៃកងពលធំ ៥០២ ចំនួនប្រហែល ៣០០នាក់ ត្រូវបានឃុំឃាំង និងបានដាក់នៅក្រោមការឃ្លាំមើលពីអ្នកយាមពី ៤០ ទៅ ៥០ នាក់។ អ្នកទោសត្រូវបានដាក់ខ្នោះដៃ ដាក់ច្រវ៉ាក់ ត្រូវបានសួរចម្លើយ ធ្វើទារុណកម្ម និងត្រូវធ្វើការងារដោយបង្ខំ[៨]។ សាក្សីរូបនេះគិតថា អ្នកទោសកម្រិតធ្ងន់ត្រូវបាននាំយកចេញពីមន្ទីរ ស២២ - យ៉ាងហោចណាស់ គឺជាកម្មាភិបាលកងពលធំ ៥០២ ដែលមានឋានន្តរសក្តិលើសពីមេបញ្ជាការកងអនុសេនាធំ[៩]។

៨. កិច្ចស៊ើបសួរបន្ថែមដ៏សំខាន់ ត្រូវបានតម្រូវឱ្យរកឱ្យឃើញនូវការពិតពាក់ព័ន្ធនឹងការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ២ និងស៊ើបសួរឱ្យបានពេញលេញអំពីបទល្មើសដែលបានប្រព្រឹត្តនៅទីកន្លែងនេះ។ កិច្ចស៊ើបសួរនេះត្រូវរួមបញ្ចូលនូវការដឹកនាំការស្តាប់យកចម្លើយពីកម្មាភិបាលដែលមានឋានន្តរសក្តិខ្ពស់នៃកងពលធំ ៥០២, កម្មាភិបាលមន្ទីរ ស២២ និងអ្នកនៅរស់រានមានជីវិតពីមន្ទីរ ស២២ ផ្សេងទៀត។ ទោះបីជាមិនមានការលើកឡើងច្បាស់លាស់ថា កិច្ចស៊ើបសួរមិនទាន់បញ្ចប់ក៏ដោយ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងសំដៅតែលើការស្តាប់យក

[៧] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ស២២, ភ្នំពេញ, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១០ (បានជូនដំណឹងនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១), ឯកសារ D2/21, ទំព័រ 2-3, 13។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារ D2/18 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D166/71។

[៨] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ស២២, ភ្នំពេញ, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១០ (បានជូនដំណឹងនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១), ឯកសារ D2/21, ទំព័រ 3។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារ D2/18 (A15, A33, A35)។

[៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារ D2/18, A18។

ចម្លើយតែមួយប៉ុណ្ណោះ (គឺការស្តាប់យកចម្លើយឈ្មោះ ស្រេង ធី) [១០]។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ឃើញថា នៅក្នុងការស្តាប់យកចម្លើយកាលពីមុន សាក្សីបានផ្តល់ឈ្មោះអ្នកដែលអាចធ្វើជាសាក្សីចំនួន ២នាក់[១១]។ ពុំមានការប៉ុនប៉ងណាមួយទំនងជាត្រូវបានធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណ ដើម្បីស្វែងរកទីកន្លែង ឬដើម្បីស្តាប់យកចម្លើយបុគ្គលទាំងអស់នោះ ឬអ្នកផ្សេងទៀតទាក់ទិនទៅនឹង មន្ទីរ ស២២ នោះឡើយ។

៩. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យធ្វើការបំពេញកិច្ចស៊ើបសួរដូចបានរៀបរាប់ខាងក្រោម ដើម្បីរកឲ្យឃើញនូវការពិតនៃការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួមទាំងការបង្កើត និងដំណើរការនៃទីកន្លែងប្រព្រឹត្តបទល្មើស ការទទួលខុសត្រូវរបស់លោក ស៊ូ មេត និង កងពលធំ ៥០២ ទាក់ទិនទៅនឹងមន្ទីរសន្តិសុខ ប្រភព សមាសភាព និងចំនួនជនរងគ្រោះសរុប បទល្មើសដែលបានប្រព្រឹត្តនៅទីកន្លែងនេះ និងការបញ្ជូនជនរងគ្រោះពីមន្ទីរសន្តិសុខ ស២២ ទៅ ស២១ ឬទៅ ស២៤។

## កិច្ចស៊ើបសួរដែលបានស្នើសុំពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស២២

១០. បញ្ហានានាដែលត្រូវស៊ើបអង្កេត៖

(ក) ការទទួលខុសត្រូវរបស់កងពលធំ ៥០២ ចំពោះមន្ទីរ ស២២ និងរចនាសម្ព័ន្ធអាជ្ញាធរជាក់លាក់ដែលស្ថិតនៅក្នុងមន្ទីរសន្តិសុខ ឬ ការទទួលខុសត្រូវរបស់កងពលធំ ៥០២ ចំពោះមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត។

(ខ) ការបង្កើត និងដំណើរការមន្ទីរសន្តិសុខ ស២២ (ឬមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត) ចំនួន និងសមាសភាពជនរងគ្រោះ នីតិវិធីពាក់ព័ន្ធនឹងការចាប់ខ្លួន ការឃុំឃាំង និងការសួរចម្លើយជនរងគ្រោះ (ប្រសិនបើមាន) លក្ខខណ្ឌនានាដែលជនរងគ្រោះជួបប្រទះពេលនៅក្នុង

---

[១០] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ស២២, ភ្នំពេញ, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១០ (បានជូនដំណឹងនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១), ឯកសារ D2/21។

[១១] បទសម្ភាសន៍ DC-Cam ជាមួយ ស្រេង ធី ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៣, D1.3.32.47, ទំព័រ 15។

ឃុំ និងការធ្វើបាបដែលជនរងគ្រោះជួបប្រទះ រួមទាំងការធ្វើការងារដោយបង្ខំ ការវាយដំ និងការធ្វើទារុណកម្ម។

(គ) តួនាទីរបស់កម្មាភិបាលកងពលធំ ៥០២ និងជាពិសេស លោក ស៊ូ មេត នៅក្នុងការចាប់ខ្លួន និងឃុំឃាំងជនរងគ្រោះនៅមន្ទីរសន្តិសុខ ស២២ ដែលក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរ ស២១, ស២៤ ឬមន្ទីរសន្តិសុខផ្សេងទៀត, កាលៈទេសៈនៃការបញ្ជូនទាំងនោះ និងបញ្ហាថាតើបុគ្គលនានាដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងចម្លើយសារភាព ដែលទទួលបាននៅមន្ទីរ ស២១ ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ និងត្រូវបានឃុំឃាំងនៅមន្ទីរ ស២២ ឬនៅមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត ដែរឬទេ។ កាលៈទេសៈដែលបុគ្គលនានាដែលបានឆ្លើយសារភាពនៅមន្ទីរ ស២២ ឬមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត ត្រូវបានកំណត់ថាជា “ខ្មាំងសត្រូវ” ឬ “ជនក្បត់” ដោយលោក ស៊ូ មេត ឬអ្នកនៅក្រោមបង្គាប់របស់គាត់ និងត្រូវបានបញ្ជូនជាបន្តបន្ទាប់ទៅកាន់មន្ទីរ ស២១, ស២៤ ឬមន្ទីរសន្តិសុខផ្សេងទៀត។

(ឃ) ការបាត់ខ្លួន និង/ឬ ការប្រហារជីវិតអ្នកទោសមន្ទីរ ស២២ ទាំងនៅក្នុងបរិវេណមន្ទីរ និងនៅកន្លែងណាមួយផ្សេងទៀតដែលស្ថិតនៅម្ដុំនោះ ក៏ដូចជាទីកន្លែងរណ្ដៅកប់សព។ និង

(ង) ជនរងគ្រោះដែលត្រូវបានដោះលែងពីមន្ទីរសន្តិសុខ ស២២ ត្រូវបានបញ្ជូនទៅកាន់អង្គភាពណាខ្លះ។

១១. កិច្ចស៊ើបសួរជាក់លាក់ដែលត្រូវធ្វើ:

(ក) ស្ដាប់យកចម្លើយសាក្សីឈ្មោះ ស្រេង ធី ជាថ្មីឡើងវិញ ពាក់ព័ន្ធនឹងទីកន្លែងរបស់ជនរងគ្រោះមន្ទីរ ស២២ និងអ្នកយាម ឬអ្នកសួរចម្លើយមន្ទីរ ស២២ ផ្សេងទៀត។

(ខ) កំណត់អត្តសញ្ញាណ និងស្ដាប់យកចម្លើយ KHĂN និង PHĂN ហៅ Rân ដែលទាំងពីរនាក់ត្រូវបានរៀបរាប់ដោយលោក ស្រេង ធី នៅក្នុងការស្ដាប់យកចម្លើយរបស់ DC-Cam នៅពេលស្ថិតនៅក្នុងឃុំនៅមន្ទីរ ស២២ - KHĂN ត្រូវបានពណ៌នាថាបានស្គាល់ “អ្នកទោសជាច្រើននាក់ និងអ្នកយាមមន្ទីរ ស២២ ជាច្រើននាក់” [១២]។

---

[១២] បទសម្ភាសន៍ DC-Cam ជាមួយ ស្រេង ធី ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៣, D1.3.32.47, ទំព័រ15។

(គ) ស្តាប់យកចម្លើយលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាថ្មីឡើងវិញ ពាក់ព័ន្ធនឹងវត្តមាន ទីកន្លែង និងដំណើរការមន្ទីរ ស២២ (ឬ មន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត) នៅពេលដែលរបាយការណ៍ជាច្រើនដែលបានផ្ញើពីលោក ស៊ូ មេត ទៅឲ្យ ឌុច បង្ហាញថា ឌុច បានដឹងថាការចាប់ខ្លួន និងការសួរចម្លើយនានាត្រូវបានធ្វើឡើងដោយលោក ស៊ូ មេត និង/ឬ អ្នកនៅក្រោមបង្គាប់គាត់ ដែលស្ថិតនៅក្នុងកងពលធំ ៥០២ មុនពេលបញ្ជូនជនក្បត់ដែលបានចោទប្រកាន់មួយចំនួនទៅកាន់មន្ទីរ ស២១ តាមរយៈមធ្យោបាយដឹកជញ្ជូនផ្ទាល់របស់កងពលធំ ៥០២[១៣]។

(ឃ) ស្តាប់យកចម្លើយ ឬស្តាប់យកចម្លើយលេខាធិការកងពលធំ/កងពលតូចជាថ្មីឡើងវិញ ឬកម្មាភិបាលនានា ដែលអាចនៅរស់រានមានជីវិត និងដែលបានចូលរួមនៅក្នុងការប្រជុំសេនាធិការនានាជាមួយលោក ស៊ូ មេត (ការប្រជុំលេខាកងពលធំ ឬគណៈកងពលធំ, កងវរៈសេនាធំ, ផ្នែកសេដ្ឋកិច្ច ឬផ្នែកភ័ស្តុភារ) [១៤] ពាក់ព័ន្ធនឹងការដឹងពីមន្ទីរសន្តិសុខ ស២២

[១៣] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត ក្នុងនាមគណៈកងពល ៥០២ មានចំណងជើងថា "សេចក្តីរាយការណ៍អំពីចម្លើយសារភាពរបស់ជនឈ្មោះ ហាំ ហង់ (Ham Hang) បន្ទាប់បានរត់៤ដង", ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.6។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត, កងពល ៥០២, ផ្ញើជូន ឌុច ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារ D1.3.23.3។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត ផ្ញើជូន ឌុច ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៧ ឯកសារ D1.3.28.35។ លិខិតកម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៧, ឯកសារ D1.3.30.17។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត ផ្ញើជូន ឌុច ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.30.16, D4.1.640, D4.1.641។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត កងពល ៥០២ ផ្ញើជូន ឌុច, ស២១, ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ D1.3.30.18 និង D4.1.642។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត ផ្ញើជូន បងឌុច ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៧៧, ឯកសារ D1.3.23.4។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត, កងពល ៥០២, ផ្ញើជូន ឌុច ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ១៩៧៧ ឯកសារ D1.3.30.22; D1.3.23.5។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យពី ស៊ូ មេត ផ្ញើជូន បងឌុច ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៧៧, ឯកសារ D1.3.23.5។

[១៤] ឧទាហរណ៍ កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៦ (D1.3.27.8), ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ (D1.3.8.2, D4.1.632), ទី ២ ខែ សីហា ឆ្នាំ ១៩៧៦ (D1.3.27.10, D4.1.79), ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៦ (D1.3.27.11), ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ (D1.3.27.12, D4.1.80), ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ (D1.3.27.13), ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ (D1.3.27.16, D4.1.82), ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ (D1.3.27.18), ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៧៦ (D1.3.27.19, D4.1.84), ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ (D1.3.27.20,D4.1.85), ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ (D1.3.27.21), ថ្ងៃទី

ឬមន្ទីរសន្តិសុខកងពលធំ ៥០២ ដែលមានស្រាប់ផ្សេងទៀត, គោលនយោបាយសេនាធិការ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ និងតួនាទីរបស់លោក ស៊ូ មេត នៅក្នុងការបោសសម្អាតនានា រួមមាន:

i. ឈ្មោះ ឆាយ, កងពលធំ ១៧៥។

ii. ឈ្មោះ វ៉ាន់, កងពលធំ ២៨០។

iii. ឈ្មោះ ភា, កងពលធំ ២១០[១៥]។

iv. (ស្លាប់យកចម្លើយជាថ្មីឡើងវិញ) ឈ្មោះ អៀង ផាន, កងពលធំ (កងពលតូចអន្តរាគមន៍) ២២១[១៦]។

v. ឈ្មោះ ឌី, កងពលធំ ៧០៣[១៧]។

(ង) ស្តាប់យកចម្លើយ ឬស្តាប់យកចម្លើយកម្មាភិបាលកងពលធំ ៥០២ ជាថ្មីឡើងវិញ អំពីវត្តមាន និងដំណើរការមន្ទីរ ស២២ (ឬ មន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត) រួមមាន:

i. (ស្តាប់យកចម្លើយជាថ្មីឡើងវិញ) ឈ្មោះ ហែន សុផល ហៅ ឈុំ (ប្រុស) ជាអតីតមេបញ្ជាការកងពលធំ ១៧០ និងជាកម្មាភិបាលជាន់ខ្ពស់កងពលធំ ៥០២[១៨] តាមការសន្មត ឈ្មោះ ផល, ជាអ្នកទីពីរបន្ទាប់ពីលោក ស៊ូ មេត ដូចដែលបានកំណត់អត្តសញ្ញាណដោយលោក ពេជ ដារី និង សេង ម៉ុន[១៩]។

---

២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ (D1.3.27.22), ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ (D1.3.27.23, D4.1.87), ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៧៦ (D1.3.8.9) និង ថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៧៧ (D1.3.27.26, D4.1.91)។

[១៥] ត្រូវបានបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គិន ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ សុខ ឈាន ជឿជាក់ថា ភា បានស្លាប់នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈៀន, ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D4.1.858។

[១៦] សូមមើល កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន, ឯកសារ D4.1.846។

[១៧] ត្រូវបានបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួក រិន, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ឯកសារ D4.1.408 ។ អៀង ផាន ជឿជាក់ថា ឌី បានស្លាប់ នៅក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀង ផាន ឯកសារ D4.1.846, ទំព័រ 4។

[១៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែន សុផល (HEN Sophal) ឯកសារ D4.1.837។

[១៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ ដារី ឯកសារ D1.3.13.7, បទសម្ភាសន៍ SOAS/HRW ជាមួយ ពេជ ដារី, ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ D1.3.13.7។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៩

ii. (ស្លាប់យកចម្លើយជាថ្មីឡើងវិញ) ឈ្មោះ សុខ ឆាយ ហៅ ឆាយ (ប្រុស) ជាប្រធានកងវរៈសេនាតូច ៥៣១ ដែលមានមូលដ្ឋាននៅពោធិចិនតុង និងទទួលបន្ទុកព្រលានយន្តហោះស៊ីវិលទាំងអស់របស់ពោធិចិនតុង ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តបាត់ដំបង[២០] និងអនុរបស់គាត់ឈ្មោះ លន់[២១]។

iii. (ស្លាប់យកចម្លើយជាថ្មីឡើងវិញ) ឈ្មោះ ចាន់ ម៉ន ហៅ ជួប សុខហែម ហៅ ខុន ជានិរសារ និងអ្នកបើកបររបស់ តាល្វៃ Ta LOVEY[២២]។

iv. មេបញ្ជាការ បៃ (ប្រុស) ជនជាតិឡាវមកពីភាគឦសាន ជាប្រធានកងវរៈសេនាតូច ៥៣២ ឬ ៥៣៣ ដែលមានមូលដ្ឋាននៅផ្សារពោធិចិនតុង[២៣] ដោយបានឡើងជំនួស យ៉ុង ច្រន (Yung Chrorn) ហៅ ហាក់[២៤]។

v. ឈ្មោះ ពេជ ដារី កម្មាភិបាលកងពលធំ ៥០២[២៥]។

vi. ឈ្មោះ ធួក (ប្រុស) ជាមេបញ្ជាការកងវរៈសេនាធំ កងពល ៥០២ និងជាលេខាធិការរបស់ To LOVEY នៅព្រលានយន្តហោះកំពង់ឆ្នាំង[២៦]។

---

និង ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.601 និង D4.1.854។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រេង ធី ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D4.1.553, ត្រង់ ERN 00282224។

[២០] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឆាយ ឯកសារ D4.1.841។ ត្រូវបានបញ្ជាក់ក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ លាង ឯកសារ D2/2។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩ និងថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.601 និង D4.1.854។

[២១] ឈ្មោះនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.854 ទំព័រ ៣។

[២២] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ម៉ន ហៅ ជួប សុខែម ហៅ ខុន ឯកសារ D4.1.508។

[២៣] ត្រូវបានបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ លាង ឯកសារ D2/2 សុខ ឆាយ ជឿថា បៃ ជាប្រធានវរសេនាតូវ ៥៣៣ និងថា គាត់បានស្លាប់ហើយ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឆាយ ឯកសារ D4.1.841 ។

[២៤] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២, A Review, ឯកសារ D9/2, លេខ 354 (ប្រភព៖ D1.3.28.147, D1.3.28.40 និង D1.3.28.24)។

[២៥] បទសម្ភាសន៍ SOAS/HRW ជាមួយ ពេជ ដារី ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ D1.3.13.7។

[២៦] ត្រូវបាបបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ឆោម, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩, ឯកសារ D4.1.822, ត្រង់ ERN 00422368។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រ៊ុន ជ័យ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D4.1.823, ត្រង់ ERN

vii. ឈ្មោះ ម៉ុន ជាមេបញ្ជាការកងវរៈសេនាធំ កងពល ៥០២ នៅព្រលានយន្តហោះកំពង់ឆ្នាំង[២៧]។

viii. ឈ្មោះ យ៉េង ដែលបានឡើងជំនួសឈ្មោះ សឿង ជាអ្នកត្រួតពិនិត្យកម្មករនៅព្រលានយន្តហោះកំពង់ឆ្នាំង[២៨]។

ix. ឈ្មោះ ផាន ពេជ អនុប្រធានផ្នែកទូរលេខ កងវរៈសេនាតូច ៥៣១ កងពល ៥០២[២៩]។

x. ឈ្មោះ នឿន (ស្រី) ដែលបានត្រួតពិនិត្យការប្រជុំស្វ័យទិតៀននានា នៅព្រលានយន្តហោះពោធិចិនតុង[៣០]។

xi. ឈ្មោះ សោម ជាសហសេវិករបស់ឈ្មោះ អ៊ូ លាង (D2/2) នៅពោធិចិនតុង[៣១]។

xii. ឈ្មោះ ដុះ ជាកម្មាភិបាលសេនាធិការដែលស្គាល់លោក ស៊ូ មេត ច្បាស់[៣២]។

xiii. ឈ្មោះ ខ្លឹង (KHLOENG) កងពល ៥០២ ជាអ្នកបើកបរឧទ្ធម្ភាចក្រ[៣៣]។

---

00426308។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃិន វ៉ាត ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៩ ឯកសារ D4.1.513, ត្រង់ ERN 00315914។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គឹម, ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០០៩ ឯកសារ D4.1.556, ត្រង់ ERN 00278685។

[២៧] ត្រូវបាបបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឿង គឹមឆុង ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D4.1.503, ត្រង់ ERN 00290658។

[២៨] ត្រូវបាបបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម នោម, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារ D4.1.822 ត្រង់ ERN 00422368។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ម៉ន ហៅ ជួប សុខុន ឬ ខុន (Khon), ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៩ ឯកសារ D4.1.508, ត្រង់ ERN 00292825។

[២៩] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន ប៊ិច ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ D4.1.242 ។ យោងក្នុង កាសែត The Cambodia Daily Weekend មានចំណងជើងថា "Let Bygones be Bygones" ចុះថ្ងៃទី ១-២ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ D1.3.7.8។

[៣០] ត្រូវបាបបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ លាង (Ou Leang), D2/2។

[៣១] ត្រូវបាបបញ្ជាក់ក្នុង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ លាង (Ou Leang), D2/2។

[៣២] ត្រូវបានបញ្ជាក់ក្នុងបទសម្ភាសន៍ SOAS/HRW ជាមួយ ពេជ ដារី ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ D1.3.13.7។

[៣៣] ត្រូវបានបញ្ជាក់ក្នុងបទសម្ភាសន៍ SOAS/HRW ពេជ ដារី ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ D1.3.13.7។

(ច) ដឹកនាំកិច្ចស៊ើបសួរបន្ថែមដើម្បីកំណត់អត្តសញ្ញាណអតីតកម្មាភិបាល, អ្នកយាម និងអ្នកទោស នៅមន្ទីរ ស២២ បន្ថែមទៀត ក៏ដូចជាអ្នកផ្សេងទៀតដែលដឹងពីដំណើរការមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត។

## តួនាទីរបស់ជនជាប់សង្ស័យ ស៊ូ មេត

## ស្ថានភាពនៃការស៊ើបអង្កេតទាក់ទិននឹង ស៊ូ មេត

១២. ទោះបីជាការស៊ើបអង្កេតដ៏តិចតួចបំផុតត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ ទាក់ទិននឹង ស៊ូ មេត[៣៤] យ៉ាងណាក៏ដោយ ក៏ភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញ ឬបញ្ជាក់ថា ស៊ូ មេត ហៅ ស៊ូ សាមេត ហៅ បង ៦៥ គឺជាលេខាកងពលធំ ៥០២ នៃកងទ័ពបដិវត្តន៍កម្ពុជា ក្នុងអំឡុងរយៈកាលក្រោមការស៊ើបអង្កេត គាត់មានការបញ្ជា អំណាច និងការត្រួតត្រាដោយផ្ទាល់ទៅលើចារីផ្ទាល់ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដូចដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងបង្ហាញថា គាត់ក៏បានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបទឧក្រិដ្ឋទាំងនោះផងដែរ។ មានភស្តុតាងផងដែរ ដែលគេជឿបានថា ស៊ូ មេត គឺជាសមាជិកនៃសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា និងជាសមាជិកគណៈ-កម្មាធិការជំនួយនៃគណៈមជ្ឈិម[៣៥] ហើយថា នៅក្នុងតួនាទីជាន់ខ្ពស់ទាំងនេះ គាត់បានចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតផែនការឧក្រិដ្ឋរួម និងនៅក្នុងការអនុវត្តផែនការនេះ។ តួនាទីរបស់គាត់ជាមេបញ្ជាការកងទ័ពអាកាសរបស់កម្ពុជាប្រជាធិបតេយ្យទាំងមូល សមាជិកភាពរបស់គាត់នៅក្នុងស្ថាប័នថ្នាក់ខ្ពស់ជាមួយបក្ស និងកងទ័ព និងទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ជាពិសេស សុន សេន កំណត់ថា គាត់គឺជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបេតេយ្យ។ វិសាលភាពនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយរូបគាត់ផ្ទាល់ និងអ្នកក្រោមបញ្ជារបស់គាត់ ចំនួនជនរងគ្រោះដ៏ច្រើន[៣៦] រយៈពេលដែលបទឧក្រិដ្ឋ

---

[៣៤] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ លាង (Ou Leang), D2/2, ណុប ហាត់ (Nop Hat) ហៅ គី ហាត (Ky Hat) ហៅ ណុប ហុន (Nop Hon), D2/3, ឈួក រិន, D6, ស្រេង ធី, D2/18, និង កាំង ហ្គេកអ៊ាវ ហៅឌុច, D12។

[៣៥] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១, D12, ត្រង់ទំព័រ៣។

[៣៦] សូមមើលជាឧទាហរណ៍ បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត៖ វិវេចនា, D9/2។

ត្រូវបានប្រព្រឹត្ត និងទីតាំងភូមិសាស្ត្រដ៏ធំដែលបទឧក្រិដ្ឋបានកើតឡើង (ពោលគឺមន្ទីរ ស២២ ស២១ និង ស២៤ ក្នុងទីក្រុងភ្នំពេញ ការដ្ឋានសាងសង់ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងទីតាំងទ័ពអាកាសផ្សេងៗទៀត) ក៏បញ្ជាក់ផងដែរថា ស៊ូ មេត គឺ ជាមនុស្សម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

១៣. ទោះបីជាភ័ស្តុតាងជាឯកសារដែលមានចំនួនច្រើន ត្រូវបានផ្ទេរពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៣ ជាពិសេសកំណត់ហេតុប្រជុំយោធា របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ដែល ស៊ូ មេត បានបញ្ជូនទៅឲ្យ ឌុច និងភ័ស្តុតាងទាក់ទិននឹងការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំងយ៉ាងណាក៏ដោយ ក៏ការស៊ើបអង្កេតមិនទាន់បញ្ចប់ទេ ពីព្រោះតួនាទីរបស់ ស៊ូ មេត ពាក់ព័ន្ធក្នុងបទឧក្រិដ្ឋមិនត្រូវបានស៊ើបអង្កេតឲ្យបានហ្មត់ចត់ និងពេញលេញឡើយ។ មានតែសាក្សីបីនាក់ប៉ុណ្ណោះ[៣៧] ដែល សាក្សីពីរនាក់ក្នុងចំណោមសាក្សីទាំងបីនាក់នោះមានការដឹងតិចតួច ឬមិនដឹងសោះអំពីសកម្មភាព របស់ ស៊ូ មេត ក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[៣៨] ត្រូវបានស្តាប់ចម្លើយស្តីពីបញ្ហានៃអំណាច និងការចូលរួមរបស់ ស៊ូ មេត នៅក្នុងផែនការឧក្រិដ្ឋរួម។ ការស្តាប់ចម្លើយ ឌុច មិនពេញលេញឡើយ ដោយសារតែបញ្ហាជាច្រើនដែលគួរតែសួរទៅ ឌុច មិនត្រូវបាន លើកឡើង ហើយឯកសារសំខាន់ៗមិនត្រូវបានបង្ហាញ ក្នុងអំឡុងពេលនៃការស្តាប់ចម្លើយ។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ផងដែរថា ទោះបីជាគាត់ជាជនជាប់សង្ស័យដែលត្រូវបាន ជាប់ពាក់ព័ន្ធតាមរយៈចម្លើយរបស់សាក្សី និងភ័ស្តុតាងជាឯកសារយ៉ាងណាក៏ដោយ (ពោលគឺនៅក្នុង ឯកសារសំណុំរឿង ០០២ ដែលផ្ទេរចូលទៅសំណុំរឿង ០០៣) ក៏ ស៊ូ មេត មិនទាន់ត្រូវបានស្តាប់ចម្លើយ ឬជូនដំណឹងថា គាត់ស្ថិតនៅក្រោមការស៊ើបអង្កេតឡើយ។ ភ័ស្តុតាងពីអ្នកដែលអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី និងម្ចាស់បណ្តឹងក៏មិនទាន់ត្រូវបានប្រមូលនៅឡើយដែរ។

---

[៣៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន, D6, ស្រេង ធី, D2/18; និង កាំង ហ្កេអ៊ាវ ហៅ ឌុច, D12។

[៣៨] ឈូក រិន និង ស្រេង ធី។

១៤. ដូច្នេះ ចាំបាច់ត្រូវមានការស៊ើបអង្កេតបន្ថែមក្នុងវិសាលភាពធំទូលាយដើម្បីស្វែងរកការពិតទាក់ទិន នឹងតួនាទីពិតប្រាកដនៅក្នុងបទឧក្រិដ្ឋរបស់ ស៊ូ មេត ជាលក្ខណៈផ្ទាល់ខ្លួន និងក្នុងនាមជាសមាជិក នៃសហឧក្រិដ្ឋកម្មរួម រួមទាំងការចូលរួមរបស់គាត់នៅក្នុងការបង្កើត និងសម្របសម្រួលផែនការ ឧក្រិដ្ឋរួម ការបញ្ជា និងការគ្រប់គ្រងរបស់គាត់លើចារីផ្ទាល់ ការចេញបទបញ្ជារបស់គាត់ឱ្យប្រព្រឹត្ត បទឧក្រិដ្ឋ ការដឹងរបស់គាត់អំពីករប្រព្រឹត្តបទឧក្រិដ្ឋ និងអតីតភាពរបស់គាត់នៅក្នុងក្បាលម៉ាស៊ីន នៃកងទ័ពបដិវត្តន៍កម្ពុជា និងបក្សកុម្មុយនិស្តកម្ពុជា។

១៥. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងជាថ្មីអំពីសំណើរបស់ខ្លួនដែលមានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថា ស៊ូ មេត គួរត្រូវបានចាប់ខ្លួន និងដាក់ក្រោមការឃុំខ្លួនបណ្តោះអាសន្ន។ ស៊ូ មេត គួរត្រូវបានជូនដំណឹងថា គាត់គឺជាកម្មវត្ថុនៃការស៊ើបអង្កេត គួរត្រូវបានផ្តល់យោបល់អំពីសិទ្ធិ របស់គាត់ និងផ្តល់ឱកាសឱ្យពិនិត្យសំណុំរឿង និងផ្តល់ភ័ស្តុតាងពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងឡាយដែល ត្រូវបានចោទប្រកាន់ និងការចូលរួមរបស់គាត់នៅក្នុងបទឧក្រិដ្ឋទាំងនោះ។

## ការស៊ើបអង្កេតដែលត្រូវបានស្នើឡើង ទាក់ទិននឹង ស៊ូ មេត

១៦. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបំពេញកិច្ចស៊ើបសួរជាក់លាក់ដូចបានពណ៌នាខាងក្រោមនេះ ដើម្បី រកឱ្យឃើញការពិតអំពីការចោទប្រកាន់នានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ រួមទាំងអង្គហេតុនានាខាងក្រោម:

(ក) តួនាទីរបស់ ស៊ូ មេត នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រួមទាំងការតែងតាំងរូបគាត់ជាអនុលេខាកងពលធំ ១។

(ខ) ការតែងតាំងរូបគាត់ជាលេខាកងពលធំ ៥០២ (កងទ័ពអាកាស) ភ្លាមៗបន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ និងការបញ្ជា អំណាច និងការគ្រប់គ្រងកងពលធំរបស់គាត់ នៅក្នុងអំឡុងរយៈពេលដែលស្ថិតក្រោមការស៊ើបអង្កេត។

(គ) សមាជិកភាពរបស់ ស៊ូ មេត នៅក្នុងគណៈកម្មាធិការជំនួយនៃគណៈកម្មាធិការមជ្ឈិមបក្ស

កុម្មុយនិស្តកម្ពុជា និងសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា និងវត្តមានរបស់គាត់នៅកិច្ចប្រជុំរបស់ស្ថាប័នទាំងនេះ ព្រមទាំងកិច្ចប្រជុំផ្សេងៗទៀត (ដូចជា កិច្ចប្រជុំជាមួយ ប៉ុល ពត នួន ជា និង/ឬ សុន សេន) ដែលនៅក្នុងកិច្ចប្រជុំទាំងនោះ បទឧក្រិដ្ឋនានា រួមទាំងការបោសសម្អាតខ្មាំងផ្ទៃក្នុង ត្រូវបានរៀបចំ ពិភាក្សា និងសម្រេចសម្រួល។

(ឃ) ការចូលរួមរបស់ ស៊ូ មេត នៅក្នុងបទឧក្រិដ្ឋនានា រួមមាន (i) ការបញ្ជា ការត្រួតត្រា និងការគ្រប់គ្រងរបស់គាត់ទៅលើចារីផ្ទាល់នៃបទឧក្រិដ្ឋនៅមន្ទីរ ស២២ របស់កងពលធំ ៥០២ មន្ទីរសន្តិសុខដទៃទៀតរបស់កងពលធំ ៥០២ ឬនៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង (ii) ការបញ្ជារបស់គាត់ ឬការអនុញ្ញាតឲ្យមានការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការសួរចម្លើយ (យូរៗម្តងដោយរូបគាត់ផ្ទាល់) ការធ្វើទារុណកម្ម និងការសម្លាប់សមាជិកកងពលធំ ៥០២ ឬសមាជិកកងពលធំដទៃទៀត ដែលត្រូវបានចាត់ទុកថាជាខ្មាំង ជនក្បត់ ឬពួកសមាសភាពដទៃទៀតដែលអាចបង្កគ្រោះថ្នាក់ ព្រមទាំងការអនុវត្តការធ្វើពលកម្មដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត (iii) ការអនុញ្ញាតរបស់គាត់ឲ្យមានការផ្ទេរអ្នកទោសក្រោមការទទួលខុសត្រូវរបស់កងពលធំ ៥០២ ទៅកាន់មន្ទីរ ស២១ ឬមន្ទីរ ស២៤ ការអាចបញ្ជូនរបស់គាត់នូវចម្លើយសារភាពពីកងពលធំ ៥០២ ទៅឲ្យមន្ទីរ ស២១ ការទទួលចម្លើយសារភាពពីមន្ទីរ ស២១ ដែលជាប់ពាក់ព័ន្ធនឹងបុគ្គលិករបស់កងពលធំ ៥០២ និងការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការចាប់ខ្លួនអ្នកដែលគេសន្មតថាជាខ្មាំង ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងចម្លើយសារភាពទាំងនោះ (iv) ការដឹងអំពីបទឧក្រិដ្ឋនានាតាមរយៈការបង្ហាញវត្តមាននៅទីកន្លែងប្រព្រឹត្តបទល្មើស ដូចជា ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការទទួលរបាយការណ៍ និងការជួបប្រាស្រ័យទាក់ទងជាមួយចារីនានា ដូចជា ឌុច និងកម្មាភិបាលជាន់ខ្ពស់នៅក្នុងកងពលធំ ៥០២ រួមទាំងកម្លាំងពិសេស ឬកម្លាំងសម្ងាត់ (v) និងការចូលរួមរបស់គាត់នៅក្នុងការបំពាក់បំប៉នឧយោបាយ ដែលតាមរយៈការបំពាក់បំប៉ននយោបាយនោះ ផែនការឧក្រិដ្ឋរួមត្រូវបានផ្សព្វផ្សាយ និងអនុវត្ត។

(ង) រចនាសម្ព័ន្ធអំណាច ឋានានុក្រម និងខ្សែសង្វាក់បញ្ជានៅក្នុងកងពលធំ ៥០២ រួមមាន៖ កងវរសេនាធំ ៥១, ៥២, ៥៣ កងវរសេនាតូច ៥០១, ៥០៣, ៥០៤, ៥០៥, ៥១១, ៥១២, ៥១៣, ៥១៤, ៥២១, ៥២២, ៥២៣, ៥២៤, ៥២៨, ៥៣១, ៥៣២, ៥៣៣, ៥៣៤, ៥៣៥

(និង អតីតកងវរសេនាតូច ១១៩, ១២១, ១២២, ១២៣, ១២៤ )។

១៧. កិច្ចស៊ើបសួរជាក់លាក់ដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងលោក ស៊ូ មេត មានដូចខាងក្រោម៖

(ក) ស្តាប់ចម្លើយ ឌុច ឡើងវិញ និងសួរសំណួរគាត់បន្ថែមទៀត ទាក់ទិននឹងការចូលរួមរបស់ ស៊ូ មេត នៅក្នុងបទឧក្រិដ្ឋនានា និងស្នើឲ្យគាត់ផ្តល់យោបល់លើឯកសារដូចខាងក្រោម៖

i. របាយការណ៍កម្ពុជាប្រជាធិបតេយ្យចំនួន ៩ ដែល ស៊ូ មេត បានបញ្ជូនឲ្យ ឌុច នៅចន្លោះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៧៦ និងថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៧ ដែលតាមរយៈរបាយការណ៍ទាំងនោះ ស៊ូ មេត ជម្រាប ឌុច ដោយផ្ទាល់ថា ដោយផ្អែកលើការវិភាគដោយផ្ទាល់ខ្លួនគាត់លើចម្លើយសារភាពពីមន្ទីរ ស២១ ចម្លើយសារភាពដែលទទួលបានពីអ្នកទោសនៅកងពលធំ ៥០២ ឬបន្ទាប់ពីការស្តាប់ចម្លើយអ្នកទោសដោយផ្ទាល់ គាត់បានកំណត់ថា ពួកគេគឺជាខ្មាំង ឬជនក្បត់ ហើយបានបញ្ជូនពួកគេទៅឲ្យ ឌុច និងបានស្នើឲ្យ ឌុច ឃុំខ្លួន និងសួរចម្លើយពួកគេ និងបញ្ជូនចម្លើយសារភាពរបស់ពួកគេមកឲ្យគាត់វិញដើម្បីឲ្យគាត់កំណត់អត្តសញ្ញាណខ្មាំងបន្ថែមទៀត[៣៩]។

ii. យ៉ាងហោចណាស់ចម្លើយសារភាពចំនួន ៥ ពីមន្ទីរ ស២១ របស់កម្មាភិបាលកងពល

---

[៣៩] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ក្នុងនាមគណៈកងពល ៥០២ មានចំណងជើងថា៖ "សេចក្តីរាយការណ៍ស្តីពីចម្លើយសារភាពរបស់ឈ្មោះ ហំ ហាង (Ham Hang) បន្ទាប់ពីបានរត់ប្អូនដង", ថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៦, D1.3.12.6។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត, កងពល ៥០២, ផ្ញើជូន ឌុច, ថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៧, D1.3.23.3។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច, ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៧, D1.3.28.35។ លិខិតកម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៧, D1.3.30.17។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច, ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៧, D1.3.30.16, D4.1.640, D4.1.641។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត, កងពល ៥០២, ផ្ញើជូន ឌុច, ស២១, ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧, D1.3.30.18 និង D4.1.642។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ជូនបង ឌុច, ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧៧, D1.3.23.4។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត, កងពល ៥០២, ផ្ញើជូន ឌុច, ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៧៧, D1.3.30.22; D1.3.23.5។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ជូនបង ឌុច ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៧៧, D1.3.23.5។

ធំ ៥០២ ដែលមានចំណារបញ្ជាក់ថា ផ្ញើជូន ស៊ូ មេត៖ ចម្លើយសារភាពរបស់ ស្រី សារឿន ដៀង ភីកា អ៊ុក វ៉ាន់ ហៅ វិន ណាយ ចាប និង សួង ហឿង[៤០]។

iii. ឯកសារបន្ថែមស្តីពីបញ្ហាសន្តិសុខនៃកងពលធំ ៥០២ ពាក់ព័ន្ធជាពិសេសអំពីការដាក់មនុស្សពីរនាក់នៅក្នុង "អង្គភាពសមាសភាពមិនល្អ"[៤១] ការចាត់ប្រភេទដោយកងពលធំ ៥០២ ទៅលើកម្មាភិបាលវ័យក្មេងចំនួន ១៤នាក់ ថាជា "ខ្មាំង" ដែលនៅតែសកម្មទោះបីជាមានការឃ្លាំមើលយ៉ាងជិតដល់យ៉ាងណាក៏ដោយ[៤២] និងការផ្ទេរពួកគេក្រោយមកទៀតទៅកាន់មន្ទីរ ស២១ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ និងការសម្លាប់នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៦[៤៣]។ បញ្ជីមួយដែលរៀបរាប់អំពីសមាសភាពនៃកងវរសេនាតូចជើងអាកាសទី២ នៃកងពលធំ ៥០២ រួមមានមនុស្សចំនួន ៩ នាក់ ដែលត្រូវបាន "យកចេញ" ដែល ៤នាក់ ក្នុងចំណោមអ្នកទាំងនោះ ត្រូវបានកត់សម្គាល់ថាជា "សមាសភាពមិនល្អ" [៤៤] ឯកសារមួយរបស់មន្ទីរ ស២៤ ដែលបញ្ជាក់

[៤០] ឯកសារសំណុំរឿងលេខ ០០២ ចម្លើយសារភាព ស២១ របស់ ស្រី សារឿន (ស្រី សារឿន), អតីតសមាជិកវរៈសេនាតូច ៥២១, កងពង ៥០២, ថ្ងៃទី៣ ខែ តុលា ឆ្នាំ ១៩៧៧ ឯកសារ D2-15.53 (ឯកសារកំពុងត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ)។ ចម្លើយសារភាព ស២១ របស់ ស្រី សារឿន (ស្រី សារឿន), ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៧, D1.3.1.10។ ឯកសារសំណុំរឿងលេខ ០០២ ចម្លើយសារភាព ស២១ របស់ ដៀង ភីកា (DEANG Phika), ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៦, អតីតប្រធានរោងពុម្ព, D288/6.2.23 (ឯកសារកំពុងត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ) ។ ចម្លើយសារភាព ស២១ របស់ អ៊ុក វ៉ាន់ (UK Van) ហៅ វិន (Vin), សមាជិក, វរសេនាតូច ៥០៣, កងពល ៥០២, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧, D1.3.1.12។ ចម្លើយសារភាព ស២១ របស់ ណាយ ចាប (NAY Chap), ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៧៧, ឯកសារ D1.3.1.5។ ចម្លើយសារភាព ស២១ របស់ សួន ហឿង (SUON Heuang), អនុលេខាវរសេនាតូច ៥១១, កងពល ៥០២, ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៧៧, D1.3.1.11។

[៤១] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ខន និង មុត, កងពល ៥០២, ជូន "បងជាទីគោរព", ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៦, D1.3.12.4។

[៤២] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីប្រភេទ ពីកងពល ៥០២ ផ្ញើជូនប្រធានគណៈកម្មាធិការ ស២១ មិនមានកាលបរិច្ឆេទ ប៉ុន្តែទំនងជាចុះកាលបរិច្ឆេទខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ ឯកសារ D1.3.12.8 និង D1.3.30.1។

[៤៣] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ A Review, D9/2, លេខ 36, 38, 84, 96, 122, 136, 167, 192, 260, 266, 267, 284, 285, 338, 343, 345, 348, 349, 354។

[៤៤] បញ្ជីឈ្មោះទាហានបដិវត្តកម្ពុជា, 01- ??-1976, D1.3.5.22។

អំពីសមាជិកកងពលធំ ៥០២ ក្នុងចំណោមអ្នកទោសដែលមានជំងឺឆ្លង[៤៥] និង

iv. បញ្ជីអ្នកទោសមន្ទីរ ស២១ ដែលមានអ្នកទោសចំនួន ៣៥៥នាក់ មកពីកងពលធំ ៥០២ ដែលចងក្រងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរួមមានឈ្មោះរបស់កម្មាភិបាលជាន់ខ្ពស់ ដូចជា លេខា/អនុលេខានៃកងអនុសេនាធំ[៤៦] សមាជិកគណៈកម្មាធិការនៃកងវរសេនាតូច[៤៧] សមាជិកគណៈកម្មាធិការនៃកងវរសេនាធំ[៤៨] សមាជិកគណៈកម្មាធិការនៃកងពលធំ ៥០២[៤៩] ឬអនុលេខានៃកងពលធំ ៥០២[៥០]។

(ខ) ពិសេសជាងនេះទៀត ស្នើឲ្យ ឌុច ឆ្លើយសំណួរនានាដូចខាងក្រោម:

i. ថាតើកងពលធំភូមិភាគកណ្តាលទាំងអស់មានមន្ទីរសន្តិសុខផ្ទាល់ខ្លួនឬយ៉ាងណា។ ថាតើ ឌុច បានដឹងអំពីវត្តមានមន្ទីរ ស២២ ដែលមានទីតាំងនៅតំបន់ស្ទឹងមានជ័យ ឬវត្តមានមន្ទីរសន្តិសុខកងពងលធំ ៥០២ ផ្សេងទៀត ដែរឬទេ។

ii. តើអ្នកទោសត្រូវបានកងពលធំ ៥០២ បញ្ជូន ពីមន្ទីរ ស២២ ឬពីមន្ទីរសន្តិសុខកងពលធំ ៥០២ ផ្សេងទៀត និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ទៅកាន់មន្ទីរ ស២១ ឬ ស២៤ នៅពេលណា និងតាមមធ្យោបាយណា។

iii. ថាតើលោក ស៊ូ មេត ធ្លាប់បានទំនាក់ទំនងជាមួយ ឌុច ដោយផ្ទាល់មាត់ដែរឬទេ ឬថាតើ

---

[៤៥] ឯកសារសំណុំរឿង ០០២ របាយការណ៍មន្ទីរ ២៤ ចុះហត្ថលេខាដោយ ហ៊ុយ មានចំណងជើងថា "ឈ្មោះអ្នកដែលកើតជម្ងឺឆ្លង" រួមទាំង ៤នាក់ មកពីកងពល ៥០២, ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៧ ឯកសារ D108/31.25 (ឯកសារកំពុងត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ)។

[៤៦] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ វិវេចនា, D9/2, ដូចជាលេខ 5, 12, 13, 17, 240, 246, 261, 272, 295, 312, 317, 323។

[៤៧] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ វិវេចនា, D9/2, លេខ 21, 45, 68, 71, 142, 166, 172, 173, 197, 207, 216, 218, 233, 274, 282, 283, 299, 303, 307, 334 និង 354។

[៤៨] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ វិវេចនា, D9/2, លេខ 37, 109, 195, 303, 342។

[៤៩] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ វិវេចនា, D9/2, លេខ 86។

[៥០] បញ្ជីឈ្មោះអ្នកទោស ស២១ ចាប់មកពីកងពល ៥០២ ចងក្រងដោយ ក.ស.ច.ស ៖ វិវេចនា, D9/2, លេខ 279។

ការទំនាក់ទំនងគ្នាត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់ពិសេសដោយឡែក តាមរយៈ កម្មាភិបាល ដទៃទៀត ឬក៏មានការពាក់ព័ន្ធជាមួយ សុន សេន ឬ នួន ជា ឬយ៉ាងណា។

iv. ថាតើវាបង្ហាញចេញពីភស្តុតាងដែលឲ្យ ឌុច ពិចារណាថា យូរៗម្តង លោក ស៊ូ មេត បានដឹកនាំការសួរចម្លើយខ្លួនឯង ឬតាមរយៈអ្នកនៅក្រោមបង្គាប់ ដើម្បីកំណត់ខ្លួនឯងថា អ្នកណាក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនពីកងពលធំ ៥០២ ជាខ្មាំងសត្រូវបង្កប់ ឬយ៉ាងណា[៥១]។ តើ ឌុច ផ្សះផ្សាបញ្ហានេះជាមួយសេចក្តីបង្គាប់បញ្ជារបស់គណៈមជ្ឈិម ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ពាក់ព័ន្ធនឹងអំណាចក្នុងការកម្ទេចខ្មាំងសត្រូវដែល នៅក្នុងជួរ និងនៅក្រៅជួរតាមវិធីណា[៥២]។ ថាតើកម្មាភិបាលយោធាមកពីកងពលធំ ៣១០ និង ៤៥០ ត្រូវបានចាប់ខ្លួនដោយប្រសិទ្ធភាពដោយកងពលធំ ៥០២[៥៣] និងត្រូវបានបញ្ជូន ទៅមន្ទីរ ស២១ ដែរឬទេ និងនៅក្រោមកាលៈទេសៈណា។ ថាតើ ឌុច បានដឹងពីប្រភព អ្នកទោសដែលត្រូវបានបញ្ជូនដោយកងពលធំ៥០២ (មន្ទីរ ស២២, ការដ្ឋានព្រលាន យន្តហោះកំពង់ឆ្នាំង, ព្រលានយន្តហោះ ឬអង្គភាពប្រតិបត្តិការផ្សេងទៀត, មន្ទីរសន្តិសុខ កងពលធំ ៥០២ ផ្សេងទៀត) ដែរឬទេ។

v. ថាតើ ចម្លើយសារភាពដែលទទួលបានពីអ្នកទោសមន្ទីរ ស២១ ត្រូវបានផ្តល់ឲ្យលោក ស៊ូ មេត ពេលខ្លះតាមសំណើសុំផ្ទាល់របស់គាត់[៥៤] ដូចដែលបានបង្ហាញតាមរយៈភស្តុតាង ខាងលើ ដែរឬទេ និងថាតើ លោក ស៊ូ មេត បានចាត់វិធានការធ្វើការស៊ើបសួរ ឬចាប់ខ្លួន ខ្មាំងសត្រូវថែមទៀតដូចដែលបានកំណត់អត្តសញ្ញាណនៅក្នុងចម្លើយសារភាពទាំងអស់

---

[៥១] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត កងពល៥០២ ផ្ញើជូន ឌុច, មន្ទីរស២១, ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧, D1.3.30.18 និង D4.1.642។

[៥២] សេចក្តីសម្រេចរបស់គណៈមជ្ឈិមកម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងបញ្ហាមួយចំនួន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦, D1.3.19.1។

[៥៣] សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៧, D1.3.28.35។ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត ផ្ញើជូន ឌុច ចុះថ្ងៃទី៤ ខែ តុលា ឆ្នាំ ១៩៧៧, D1.3.23.5។

[៥៤] សូមមើលជាឧទាហរណ៍ សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ូ មេត កងពល ៥០២ ផ្ញើជូន ឌុច ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៧៧, D1.3.30.22។

នោះដែរឬទេ។ ជាពិសេស ស.ច.ស ត្រូវពិនិត្យមើលចម្លើយសារភាពពីមន្ទីរ ស២១ ដែលបានលាតត្រដាងថ្មីៗ រកឲ្យបាននូវចម្លើយសារភាពស្តីពី មន្ទីរ ស២១ របស់អតីតកម្មាភិបាលដែលមកពីអង្គភាព កងអនុសេនាធំ កងវរៈសេនាតូច និងកងវរៈសេនាធំ ដែលស្ថិតនៅក្នុងកងពលធំ ៥០២ ផ្សេងទៀតទាំងអស់ ពិនិត្យមើលចម្លើយសារភាពទាំងនោះចំពោះចំណារណាមួយដែលនិយាយពី ស៊្វ មេត រួចហើយស្នើឲ្យ ឌុច ផ្តល់យោបល់លើចំណារនោះ។

vi. ថាតើ ចម្លើយសារភាពដែលទទួលបានមកពីអ្នកទោសកងពលធំ ៥០២ ត្រូវបានបញ្ជូនទៅឲ្យ ឌុច រួមជាមួយអ្នកទោសដែលបានបញ្ជូនពីកងពលធំ ៥០២ ទៅមន្ទីរ ស២១ ដែរឬទេ។ តើលក្ខខណ្ឌណាមួយ (ឋានៈ, តួនាទី, បណ្តាញក្បត់, ចម្លើយសារភាព មិនច្បាស់លាស់ដែលតម្រូវឲ្យមានជំនាញសួរចម្លើយជាក់លាក់ ជាដើម) ឬការបង្គាប់បញ្ជាណាមួយដែលបានកំណត់ឲ្យលោក ស៊្វ មេត បញ្ជូនអ្នកទោសទៅកាន់មន្ទីរ ស២១។

vii. តើអ្នកណាជាអ្នកសរសេរចំណារនានានៅលើរបាយការណ៍ដែលផ្ញើពីលោក ស៊្វ មេត ទៅឲ្យ ឌុច ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧៧ ("សួរ [គាត់] ឥឡូវនេះ")។ តើអ្នកណាបានធ្វើចំណារចម្លើយសារភាពស្តីពីមន្ទីរ ស២១ របស់កម្មាភិបាលកងពលធំ ៥០២ ទាំងប្រាំដែលបានលើកឡើងខាងលើ ដែលបង្ហាញថា ចម្លើយសារភាពទាំងនោះត្រូវបានបញ្ជូនទៅឲ្យលោក ស៊្វ មេត ហើយ។

viii. បរិយាយឲ្យបានពិស្តារនូវការលើកឡើងរបស់គាត់ដូចខាងក្រោម ដែលបានធ្វើឡើងនៅក្នុងពេលស្តាប់យកចម្លើយដែលបានធ្វើឡើងនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១៖ "ជាមួយគ្នាផងដែរ មុនពេលធ្វើសេចក្តីសម្រេច សុន សេន... តែងតែបានស្នើសុំយោបល់ និងជំនួយពីប្រធានផ្នែកនានា"[៥៥]។ ជាពិសេសគាត់ត្រូវបានគេស្នើសុំឲ្យពន្យល់អំពីតើរឿងនេះ មានការទាក់ទិននឹងភាពពាក់ព័ន្ធរបស់លោក ស៊្វ មេត នៅក្នុងការបោសសម្អាត និងការងាររបស់សេនាធិការកងទ័ពបដិវត្តន៍កម្ពុជា យ៉ាងដូចម្តេច។

ix. ពណ៌នាអំពីការប្រជុំទាំងអស់ (រួមទាំងការប្រជុំសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា/កង

[៥៥] កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១ ឯកសារ D12, ត្រង់ទំព័រ៥។

ពលធំ និងវគ្គសិក្សាធំជាងនេះ) ដែលគាត់បានចូលរួមដែលពេលនោះ លោក ស៊ូ មេត មានវត្តមានផងដែរ និង

x. កំណត់ឈ្មោះកម្មាភិបាលដែលនៅរស់រានមានជីវិតផ្សេងទៀតដែលធ្លាប់ដឹងច្បាស់ពីតួនាទី និងសកម្មភាពរបស់លោក ស៊ូ មេត នៅក្នុងអំឡុងពេលស៊ើបអង្កេត។

(គ) ស្តាប់យកចម្លើយឈ្មោះ ហ៊ឹម ហ៊ុយ, ម៉ម ណៃ ឬកម្មាភិបាលមន្ទីរ ស២១ ផ្សេងទៀត និរសារ ឬអ្នកយាម ទាក់ទិននឹងវត្តមានមន្ទីរសន្តិសុខ ស២២ ការបោសសម្អាតនៅក្នុងកងពលធំ ៥០២ ការបញ្ជូនអ្នកទោសទៅកាន់មន្ទីរ ស២១ ឬ ស២៤ ដោយកងពលធំ ៥០២ ក្រោយពេលចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយពួកគាត់ដោយកងកម្លាំងពិសេសរបស់កងពលធំ ៥០២ ការទំនាក់ទំនងរវាងកងពលធំ ៥០២ និង មន្ទីរ ស២១ តាមរយៈនិរសារ ទូរស័ព្ទ ឬទូរលេខ ការផ្លាស់ប្តូរចម្លើយសារភាពរវាងមន្ទីរ ស២១ និងកងពលធំ ៥០២។

(ឃ) ស្តាប់យកចម្លើយ ឬសម្តាប់យកចម្លើយ ក.ស.ច.ស ជាថ្មីឡើងវិញ DC-Cam ឬ SOAS/HRW សាក្សីសំណុំរឿង ០០២ ពាក់ព័ន្ធនឹងសិទ្ធិអំណាចជាក់លាក់ , តួនាទី, ការទទួលខុសត្រូវ និងកាចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ របស់លោក ស៊ូ មេត រួមទាំង ប៉ុន្តែមិនកំណត់ចំពោះ៖ ហែន សុផល ហៅ ឈុំ ហៅ ផល[៥៦]។ សុខ ឆាយ ហៅ ឆាយ[៥៧]។ ចាន់ ម៉ន នៅ ជួប សុខហែម ហៅ ខុន[៥៨]។ ហឿន ភ័ត ហៅ ភាព[៥៩]។ កែវ លឿ ហៅ កែវ សុផល[៦០]។ ពេជ ដារី[៦១]។ ភី យុន[៦២]។ ផាន ពេជ ហៅ ពេជ[៦៣]។ សេង ម៉ុន[៦៤]។ សេត ពៅ[៦៥]។ កែវ គិន[៦៦]។

---

[៥៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែន សុផល ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ D4.1.837។

[៥៧] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឆាយ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ឯកសារ D4.1.841។

[៥៨] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ម៉ន ហៅ ជួប សុខែម ហៅ ខុន ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៩ ឯកសារ D4.1.508។

[៥៩] បទសម្ភាសន៍ SOAS/HRW ជាមួយ ហឿន ភ័ត ហៅ ភាព ឯកសារ D1.3.13.3។

[៦០] បទសម្ភាសន៍ DC-Cam ជាមួយ កែវ លឿ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ឯកសារ D1.3.32.18។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ លឿ ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៨, ឯកសារ D4.1.1147។

[៦១] បទសម្ភាសន៍ SOAS/HRW ជាមួយ ពេជ ដារី ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ ឯកសារ D1.3.13.7។

[៦២] ទោះបីជាគាត់ត្រូវបានគេរាយការណ៍ថាបានស្លាប់ ក្នុងឯកសារ D2/1, សហចៅក្រមស៊ើបអង្កេត ត្រូវបានណែនាំឲ្យប្រមូលភស្តុតាងទាក់ទងនឹងបញ្ហានេះ។ បទសម្ភាសន៍ DC-Cam ជាមួយ ភី យុន, ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ ឯកសារ D1.3.32.31។

(ង) ដឹកនាំការប្រឈមមុខរវាងសាក្សីដែលបានកំណត់អត្តសញ្ញាណខាងលើ ករណីចាំបាច់ ដើម្បីពិនិត្យ និងបញ្ជាក់ពីព័ត៌មាន រួមទាំងការសួរតទល់មុខរវាង ផាន ពេជ ហៅ ពេជ និង សុខ ឆាយ ហៅ ឆាយ និងការសួរតទល់មុខមួយ រវាង ពេជ ដារី និង សេង ម៉ុន និង ហែន សុផល ហៅ ឈុំ ហៅ ផល។

(ច) ស្តាប់ចម្លើយសាក្សី សិន សុត SIN Sot ដែល ឈូក រិន បានរៀបរាប់ថា ៉ជាអតីតៈទាហានខ្មែរក្រហម ហើយបច្ចុប្បន្នជាអ្នកទោសនៅពន្ធនាគារព្រៃសរ ដែលធ្លាប់ធ្វើការជាមួយ ស៊ូ មេត។[៦៧]

(ឆ) ដឹកនាំកិច្ចស៊ើបសួរដើម្បីកំណត់អត្តសញ្ញាណកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបន្ថែម និងសមាជិកកងពលធំ ៥០២ ដែលបានដឹងច្បាស់ពីតួនាទីរបស់លោក ស៊ូ មេត ក្នុងអំឡុងពេលស៊ើបសួរ ដឹងពីសាវតាររបស់គាត់មុនខែ មេសា ឆ្នាំ ១៩៧៥ និងតួនាទីបន្តទៀតរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយខែ មករា ឆ្នាំ ១៩៧៩។

១៨. ស្តាប់យកចម្លើយជនជាប់ចោទ នៅក្នុងសំណុំរឿង ០០២ ចំនួន ៤រូប (នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ) ពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់លោក ស៊ូ មេត រួមទាំងសមាជិកភាព របស់គាត់នៅក្នុងគណៈជំនួយនៃគណៈមជ្ឈិម

---

[៦៣] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ ដារី ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ D4.1.242។ យោងក្នុងកាសែត Cambodia Daily Weekend មានចំណងជើងថា "Let Bygones be Bygones", ចុះថ្ងៃទី ១-២ ខែមីនា ឆ្នាំ ២០០៨ ឯកសារ D1.3.7.8។

[៦៤] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ម៉ុន ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ និង ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ D4.1.601 និង D4.1.854។

[៦៥] សំណុំរឿងលេខ ០០២ បទសម្ភាសន៍ SOAS/HRW ជាមួយ សេត ពៅ (Set Pov), ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ឯកសារ D224.34 (ឯកសារកំពុងត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ)។

[៦៦] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ គិន (Kev Kin), ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ D4.1.504។

៦៧ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន ហៅ សុខចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០១១ ឯកសារ D6។ ឈ្មោះ សិន សុត SIN Sot នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ ឈូក រិន ហាក់ដូចជាមនុស្សផ្សេងពីសាក្សី សិន សុត Sin Sot ដែលបានស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង០០២ ដោយ ស.ច.ស (១៧ កុម្ភៈ២០០៩, D4.1.506) និង DC-Cam (២៣ កុម្ភៈ ២០០៣, D1.3.32.2 )។

ព្រមទាំងសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា ភាពជាអ្នក ដឹកនាំកងពលធំ ៥០២ របស់គាត់ និងអន្តរកម្មរបស់គាត់ជាមួយ និងឥទ្ធិពលទៅលើ សុន សេន ចំពោះវិសាលភាពដែល ថា សាក្សីម្នាក់បានហៅគាត់ថា "តាមហេតុការណ៍ពិត លេខ ២ បន្ទាប់ពី សុន សេន" [៦៨]។

១៩. កោះអញ្ជើញលោក ស៊ូ មេត ជូនដំណឹងគាត់អំពីបញ្ហានានាដែលគេត្រូវធ្វើការស៊ើបអង្កេតពីគាត់ ជូនដំណឹងគាត់អំពីសិទ្ធិរបស់គាត់ និងផ្តល់ឱកាសឲ្យគាត់ឆ្លើយសំណួរ និងផ្តល់ភស្តុតាងពាក់ព័ន្ធនឹង បញ្ហាទាំងអស់ដែលបានពណ៌នាខាងលើ និងការចោទប្រកាន់លើគាត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរ។

## សន្និដ្ឋាន

២០. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យ ស.ច.ស៖

(ក) ចាត់វិធានការស៊ើបសួរទាំងអស់ដែលបានពណ៌នាខាងលើ។

(ខ) ធ្វើសកម្មភាពបន្ថែមទាំងអស់ដែលចាំបាច់ នៅពេលមានលទ្ធផលនៃកិច្ចស៊ើបសួរទាំងនោះ។

(គ) ដាក់ភស្តុតាងដែលប្រមូលបានជាផ្នែកមួយនៃកិច្ចស៊ើបសួរទាំងនោះចូលក្នុងសំណុំរឿង នៅពេលទទួលបានភស្តុតាងទាំងនោះភ្លាម។

សូមទទួលនូវការគោរពរាប់អានពីយើងខ្ញុំ៖

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ | Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and seal: CO-PROSECUTORS CO-PROCUREURS] |

[៦៨] SOAS/HRW សម្ភាសន៍ ពេជ ដារី (២៧ កក្កដា២០០៥, D1.3.13.2 )។